# ក្មេងវត្ត

និង

# ក្មេងសាលាបារាំង




ដោយ **ជួត ខៀវ** ខ្មែរ អានថា **ជុត ខៃ**

កម្លោះស្កក់ទៅហើយ អាឆៃមិនទាន់ចេះន-មោនឹងគេទេ ព្រោះម៉ែឪវាឱ្យទៅឃ្វាលគោ ដាំថ្នាំ ដាំពោត ។ អាឆៃកើតនៅភូមិកៀនជ្រៃ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ កៀនជ្រៃស្ថិតនៅតាមដងទន្លេមេគង្គ មិនឆ្ងាយប៉ុន្មានពីក្រុងកំពង់ចាមឡើយ ។ ឪពុកម្ដាយអាឆៃជាអ្នកចំការ រកស៊ីដាំថ្នាំ ពោត សណ្ដែក ។ល។ គាត់ជាពុទ្ធសាសនិកជនដែលជឿព្រះពុទ្ធឥតមានព្រំដែន ។ បើឥតលុយធ្វើបុណ្យ សុខចិត្តលក់ស្រែចំការយកលុយមកធ្វើបុណ្យផ្កាឬកឋិន ។ ចំណែកអាកូនៗសុំទោស ឯងខ្វះបាយស៊ីខ្វះមួយលើកសិនទៅ ព្រោះអញចង់ឡើងស្ថានសួគ៌ ។ ឪពុកម្ដាយអាឆៃ មានកូនទាំងអស់១១នាក់ អាឆៃជាកូនពៅ ។

## វត្តថ្មគោល

ថ្ងៃមួយនោះ ឮថាបារាំងដើរចាប់ក្មេងឃ្វាលគោឱ្យទៅរៀននៅសាលាបារាំង ព្រោះសិស្សចេះតែរត់លួនមិនចង់រៀនសូត្រសោះ ។ ក្រោយពីបានពត៌មាននេះភ្លាម ឪពុកអាឆៃក៏បញ្ជូនវាឱ្យទៅនៅវត្តថ្មគោល ចម្ងាយប្រហែល៥ គ.ម ពីផ្សារកំពង់ចាម ។

នៅក្បែររបងវត្តគេឃើញមានសំណង់តូចមួយ (មិនខុសពីខ្ទមអ្នកតា) ធ្វើអំពីឫស្សី ដំបូលប្រក់ស្បូវ ។ សំណង់នេះគេធ្វើឡើងសំរាប់ការពារថ្មមួយដុំ កុំឱ្យត្រូវទឹកភ្លៀងឬពន្លឺថ្ងៃ ។ ថ្មនោះដុះផុតពីដី មានកំពស់ប្រហែលមួយម៉ែត្រ ។ ចំណែកក្បាលវាស្រួចមិនខុសពីក្បាលដែកគោលប៉ុន្មានទេ ។ អ្នកភូមិតែងតែគោរពថ្មនោះ មិនខុសពីគេគោរពអ្នកតា ។ ដោយសារថ្មនេះហើយ ទើបគេឱ្យឈ្មោះវត្តនេះថាជាវត្តថ្មគោល ។

វត្តនេះជាវត្តមួយគួរឱ្យចម្លែក ព្រោះលោកសង្ឃដែលគង់នៅទីនោះ ចែកជាពីរគណៈ "អែវម៉ែ" និង "អេវម៉េ" មានន័យថាធម៌បូរាណ និង ធម៌សម័យ ឬមានន័យម្យ៉ាងទៀតថា "ថ្ពេរសំប៉ែត" និង "ថ្ពេរមូល" ។ បានជាគេហៅថ្ពេរសំប៉ែត ព្រោះស្បង់ចីពររបស់លោកសង្ឃធម៌បូរាណ មានថ្ពេរសំប៉ែត ចំណែកលោកសង្ឃសម័យ ថ្ពេររាងមូលនៅលើស្បង់ចីវរ ។ មានលក្ខណៈពីរទៀតដែលខុសគ្នា ។ ខាងបូរាណលោកនេនយកស្បង់ចីវរមកគ្រង ចំណែកខាងសម័យលោកនេនឃ្លុំ នៅពេលដែលលោកនិមន្តទៅបិណ្ឌបាត ឬទៅណាម្តងៗ ។

វត្តមួយ "សង្ក្រាជ" ពីរ មិនខុសពីភ្នំមួយមានខ្លាពីរ ។ ដល់អញ្ចឹងទៅ លោកសង្ឃក៏មិនសូវត្រូវគ្នា អាក្មេងលោកក៏ឈ្លោះគ្នាមិនស្ងាង ។ មិនត្រឹមតែមនុស្សឈ្លោះគ្នា អាឆ្កែក៏មិនត្រូវគ្នាដែរ ។ ឆ្កែខាង "អែវម៉ែ" ឃើញឆ្កែខាង "អេវម៉េ" មិនបាន គឺគ្រហឹមខាំគ្នាយកស្លាប់យករស់តែម្តង ។

លោកគ្រូ "សង្ក្រាជ" ខាងធម៌បូរាណ មានព្រះនាមថាលោកគ្រូអាចារ្យហៃ ។ ចំណែកខាងសម័យមានព្រះនាមថា លោកគ្រូអាចារ្យថៅ ។ លោកគ្រូ "សង្ក្រាជ" ទាំងពីរអង្គ មានលោកគ្រូសូត្រមួយម្នាក់ៗ ។ ការដែលគួរឱ្យកត់សំគាល់នោះ គឺលោកគ្រូសូត្រទាំងពីរគណៈមានព្រះនេត្រខ្វាក់ដូចៗគ្នា ។

អាឆៃនៅកុដិលោកគ្រូអាចារ្យថៅ ។ ក្មេងវត្តខាងអាចារ្យថៅមានទាំងអស់ប្រហែល៣០នាក់ ។ អាមាឌធំៗក្បាលកញ្ជាស់ ដូចអាឆៃមាន៥ ឬ៦ នាក់ ។ នៅពេលភ្នំបិណ្ឌម្តងៗ អាឆៃតែងតែនាំក្មេងវត្តអឹតករហបនៅលើកុដិដើម្បីអ៊ុតមើលអ្នកទូលនំអន្សម ផ្លែឈើ ម្ហូបម្ហាមកប្រគេនលោក ថាតើអ្នកទាំងអស់នោះទៅកុដុអាចារ្យថៅ ឬអាចារ្យហៃ ។ បើឃើញអ្នកធ្វើបុណ្យដើរសំដៅមកកុដិអាចារ្យថៅ អាឆៃនិងគូកនវាសប្បាយរីករាយណាស់ ។ បើឃើញឧបាសក ឧបាសិកា ណាដើរសំដៅទៅកុដិអាចារ្យហៃ វាប្រទេចផ្តាសាថា ជាពួកអា "អែវម៉ែ" បូរាណចាស់គំរិល ។

នៅខាងលោកធម៌សម័យគេឃើញមានកុដិធំៗពីរ គឺកុដិលោកគ្រូ "សង្ក្រាជ" និងលោកគ្រូសូត្រ ។ ក្រៅពីកុដិគេឃើញមានតូប៥ ទៀត ។ កុដិនិងតូបទាំងនោះ សង់អំពីឈើប្រក់ក្បឿង ។ លោកសង្ឃខាងសម័យមានប្រហែល៥០អង្គ ភិក្ខុ១២អង្គ នេន៣៨អង្គ ។ កុដិលោកគ្រូអាចារ្យថៅធំជាងគេ ហើយសង់នៅជិតព្រះវិហារ ។ កុដិនេះអាចដាក់មនុស្សបានយ៉ាងតិច១០០នាក់ ព្រោះសាលាឆាន់ សាលារៀន ក៏នៅក្នុងកុដិនេះដែរ ។ ក្មេងវត្តម្នាក់ៗសុទ្ធតែមានលោកគ្រូបង្ហាត់អក្សរម្នាក់មួយៗ ដែលភាគច្រើនៗតែនេន ។ លោកគ្រូអាឆៃឈ្មោះលោកគ្រូរ៉េត ជាលោកនេនមួយអង្គចាស់វស្សាជាងគេ លោកសង្ឃយកចិត្តទុកដាក់បង្រៀនអក្សរក្មេងៗ ចំណែកក្មេងៗត្រូវតបស្នងសងគុណលោកគ្រូ ដោយដាំទឹកក្តៅប្រគេនលោក ឬគក់ច្រចាច់នៅពេលលោកឈឺថ្កាត់ម្តងៗ ។ ដោយក្មេងៗគ្មានស្លាបព្រាស៊ី

បាយនៅពេលលោកឆាន់រួច លោកគ្រូម្នាក់ត្រូវប្រគល់ស្លាបព្រាព្រះអង្គទៅសិស្សរៀងៗខ្លួន ។ បើគិតពីរឿងស្លាបព្រា គ្រូនិងសិស្សមានឋានៈស្មើគ្នា ព្រោះស្លាបព្រាមួយមានម្ចាស់ពីរ ។ លោកគ្រូឆាន់រួច សិស្សស៊ីក្រោយ ដល់សិស្សស៊ីរួច លោកគ្រូឆាន់ក្រោយ ។ វិលទៅវិលមក មិនដឹងជាសិស្ស ឬលោកគ្រូទេ ដែលបានស្លាបព្រាស៊ី ឬឆាន់បាយមុន ។ ស្លាបព្រានេនរ៉េត គ្រូអាឆៃធ្វើអំពីស្ពាន់ មានពណ៌លឿង ក្បាលចង់ប៉ិនក្បាលវែក ។ លោកគ្រូរ៉េតរអ៊ូរាល់ថ្ងៃ ដោយសារតែវាស៊ីបាយរួច លាងស្លាបព្រាមិនជ្រះ ។ យូរៗអាឆៃយកស្លាបព្រានោះទៅដុសនឹងផេះម្តងៗ។

វត្តថ្មគោល ជាវត្តមួយសង់នៅលើដីដ៏ធំធេង ។ នៅក្នុងវត្តគេឃើញមានដើមចំប៉ា ដើមត្នោត ដើមបេង និងចំការទៀប ។ នៅពេលថ្ងៃសីល ឈប់សំរាក អាឆៃតែងតែដើររើសបេង ទៅឱ្យម្តាយវាឯគៀនជ្រៃ ។ គ្រាប់បេងមានសំបកខ្មៅហើយមានប្រយោជន៍សំរាប់អ្នកម្ហូរចារីលក់ ។ ក្រោយពីយកសំបកវាចេញ គេយកគ្រាប់បេងទៅដុសក្នុងចានថ្ម ។ លុះដុសបានបន្តិចមក ទឹកក្នុងចានក្លាយទៅជាខាប់ ប្រហែលនឹងទឹកបាយម៉ាន រួចហើយគេយកដំបារសំឡីជ្រលក់ក្នុងទឹកនោះ មកបិទលើក្រដាសជក់ម្ហូរចារី ។ ម្តាយអាឆៃគាត់តែងតែម្ហូរចារីមកប្រគេនលោករគូធំជានិច្ច នៅពេលវាបានច្បាប់ទៅលេងផ្ទះម្តងៗ ។

រឿងចម្លែកមួយទៀតនៅវត្តថ្មគោល គឺត្រង់ព្រះសង្ឃទាំងពីរគណៈមានបង្គន់រួម ។ បើលោកនិមន្តទៅបង្គន់រួមជួបគ្នា ហាក់ដូចជាត្រូវគ្នា តែលោតែជួបគ្នានៅពេលបិណ្ឌបាត្រវិញ សង្រ្គឹតដាក់គ្នា សឹងតែរបូតស្បង់ចីពរអស់ហើយ ។ បង្គន់នោះធ្វើអំពីឈើ សង់ខ្ពស់ពីដីប្រហែលបួនម៉ែត្រ ។ បន្ទប់បត់ជើងមានទៅ១៥ ហើយមានជណ្តើរឡើងពីរនៅសងខាងបង្គន់ ។ ខាងក្រោមទទេស្អាតគ្មានអ្វីបិទបាំងទេ ។ បើសិនជាអ្នកដំណើរណាម្នាក់វង្វេងផ្លូវដើរទៅក្បែរបង្គន់នោះ ច្បាស់ជាយល់ច្រឡំថា មានដំបូក១៥ នៅក្រោមសាលាឆាន់ តែតាមពិតគឺគំនរលាមកសោះ ដែលយូរទៅកាន់តែខ្ពស់ឡើង ខ្ពស់ឡើង សឹងទើសក្តារ ។ បង្គន់នេះសង់នៅឆ្ងាយពីកុដិប្រហែល៥០០ម៉ែត្រ តែនៅពេលខ្យល់បក់ខ្លាំងមកម្តងៗ ក្លិនស្អុយជះមកដល់កុដិសឹងតែដកដង្ហើមមិនរួច ។

ចំណែកឯក្មេងៗវិញគ្មានសំណាងបានទៅបត់ជើងនៅបង្គន់រួមនោះទេ ។ វានាំគ្នាទៅលេងឯចំការទៀប ។ ចំណែកថ្មនៅក្បែងចំការ រលោងដូចបាត្រលោក អស់ទៅហើយ ព្រោះក្រោយពីបត់ជើងរួច វាយកគូទវាទៅកកិតលើថ្ម មិនខុសពីសត្វសុនខខ្មែរជុះអាចម៍មានព្រូន អូសគូទវានៅលើដី ព្រោះវារមាស់ក្តិតខ្លាំងពេក ។ បើតាមខ្ញុំដឹង ដុំថ្មទាំងនោះបានត្រូវពួកអាក្មេងវត្តជាឧបករណ៍មកអស់ជាច្រើនដំណណាស់មកហើយ ( ខ្ញុំធ្លាប់នៅវត្តថ្មគោល ជាមួយអាឆៃ ) ។

ម្ភៃឆ្នាំក្រោយមក ខ្ញុំជួបអាឆៃនៅឯភ្នំពេញ វាប្រាប់ខ្ញុំថាវាកើតឫសដូងបាត ព្រោះតែកកិតគូទនឹងថ្មនៅវត្តថ្មគោល ។ ចៃដន្យអីខ្ញុំក៏កើតឫសដូងបាតដែរ ។ បើដូចនេះមើលទៅក្មេងវត្តថ្មគោលប្រហែលជាកើតជម្ងឺនេះទាំងអស់គ្នា ។

ក្នុងចំណោមក្មេងវត្ត ក្រៅពីអាឆៃមានពីរ-បីនាក់ទៀត ដែលសុទ្ធតែក្បាល "គ្រាក់ៗ" គឺ៖ អាទិត អាជួន អាជ្រឹង ។ អាក្រោយនេះធំដូចឃ្មោក តែរៀនមិនទៅមុខសោះ ហើយរបៀបដូចជាគ្រាសកន្ទួងផង ។ អ្នកមកនៅវត្តស្រករវាគេបួសអស់ទៅហើយ តែអាជ្រឹងមិនទាន់មើលសស្រ្តាកេរ្តិ៍កាលចប់ផង ។ មួយថ្ងៃៗ ក្រោយពីលោកឆាន់បាយថ្ងៃត្រង់រួច គេឮតែសម្លេងអាជ្រឹងស្រែកខ្លែងៗ៖ "កេរ្តិ៍ពីព្រេងព្រិទ្ធ សាងសុចរិតទុករៀងទៅ សេដ្ឋីផ្តាំប្រដៅ..." ។ លោកគ្រូអាជ្រឹងឈ្មោះលោកគ្រូគង់ ។

ថ្ងៃមួយវារៀនប្រកបជាមួយលោកគ្រូវា៖ ខ ដាក់ជើង ម ខ្ម... ក ដាក់ជើង ម ក្ម...។ លុះដល់ដាក់ជើង ដ អាជ្រឹងមិនហ៊ានថា ។ អាជ្រឹងស្រែកទូលលោកគ្រូវា៖

- តេជគុណខ្ញុំ "កាណា" មិនហ៊ានថាទេ

- ម៉េចឯងមិនហ៊ានថា? (លោកគ្រូគង់ សួរ)

- ខ្ញុំ "កាណា" មិនហ៊ានថាទេតេជគុណ ។

-ថាទៅមើលស្អី?

ដោយលោកគ្រូបង្ខំពេក អាជ្រឹងក៏ស្រែកប្រកប ក ដាក់ជើង ដ ក្ត

-យី អា"ល្បល់យ"អញស្មានថាស្អី ។ មើល៍ បន្តទៅទៀតមើល ។

អាជ្រឹងបន្តទៅទៀត ច ដាក់ជើង យ ÷ ច្យ ដាក់ស្រះ (ុ)

-ទេ ខ្ញុំ កាណាមិនហ៊ានថាទេ តេជគុណ ។

-យីស្អីទៀតហើយអាជ្រឹង ។ មើល៍ យកមកឱ្យអញមើល មើល៍ ។ លោកគ្រូគង់យកអក្សរមកពិនិត្យ ។

-យីអានេះចំតែម្តង ឯងមិនឃើញអក្សរ តនៅមុខទេឬ? អាហ្នឹងអានថា"ចយ៉ុត" (ច្យុត) មិនមែនដូចឯងគិតផ្តេសផ្តាសនោះទេ ។ (ច្យុ= សូមអស់លោកអ្នកអានពិចារណាទៅផងចុះ ព្រោះអាហ្នឹងជាអក្សរ បូរាណខ្មែរ ។ អាជ្រឹងវាគិតទៅរឿងម្យ៉ាងហ្នុងឯង) ។

ថ្ងៃមួយនោះ ជាថ្ងៃពេញបូណ៌មី ។ នៅពេលល្ងាចក្រោយព្រះអាទិត្យអស្តង្គត អ្នកឡើងត្នោត បីបួននាក់ បានវែកទឹកត្នោតជាច្រើនបំពង់មកប្រគេនលោក ។ ដោយសារថ្ងៃនោះជាថ្ងៃសីល ក្មេងជាច្រើនបានត្រូវលោកគ្រូ ធំអនុញ្ញាតឱ្យទៅលេងផ្ទះ នៅសល់តែបីបួននាក់អាជ្រឹង អាម៉េន អាឆៃ អាទិត ជាដើម ។ ក្រោយពីលោកគ្រូធំចែកចាយទឹកត្នោតទៅលោកសង្ឃឯទៀតរួចរាល់អស់ហើយ លោកក៏មានពុទ្ធដីកាទៅកាន់អាបីបួននាក់នោះ ថា៖

-ឯង នាំគ្នារើសយក បំពង់ទឹកត្នោត តាមដែលឯងស្រឡាញ់ ទៅចុះ ។

អាឆៃសប្បាយចិត្តណាស់ ព្រោះវាខាន ផឹកទឹកត្នោត យូរណាស់មកហើយ ។ វាស្ទុះទៅយកអាបំពង់ដែលធំជាងគេ មកផឹកសឹងតែមិនដកដង្ហើម ។ លុះអស់មួយបំពង់ហើយ អាឆៃនៅតែសម្លឹងមើលទឹកត្នោតនៅសល់ធ្វើភ្នែកភ្លៀកៗ ។

-ឯងមកយកមួយបំពង់ទៀតទៅអាឆៃ (លោកគ្រូធំមានពុទ្ធដីកា) តែប្រយ័ត្នឈឺពោះរើយ ។

អាឆៃស្ទុះទៅយកមួយបំពង់ទៀត...

រាត្រីខែភ្លឺនៅស្រុកស្រែ ។ ខ្យល់បក់វេរើយៗ ធ្វើឱ្យស្លឹកចេកនៅក្បែរកុដិទង្គិចគ្នាឮសូរប្រាវៗ ។ សម្លេងខ្លែងឯកឮសូររវើយៗ ។ នៅកុដិលោកគ្រូធំ ព្រះសង្ឃ និងក្មេងៗនិទ្រាលក់យ៉ាងស្កប់ស្កល់ ។ គេឮតែស្នូរសម្លេងស្រមុកខែៗ ។ លុះដល់ជិតភ្លឺ គេឮសម្លេងប្រេសប្រសៗ ដូចជាមនុស្សរាវរកអ្វីនៅក្នុងកុដិ ។ គួរកត់សំគាល់ថា នៅក្នុងកុដិលោកគ្រូធំ ក្រោយពីបិទទ្វារដេកនៅពេលយប់ហើយ គឺងងឹតឈឹងតែម្តង ។ សម្លេងប្រេសប្រសនេះ គឺជាសម្លេងអាឆៃ វារាវរកទ្វារបើកចេញទៅក្រៅ ព្រោះវារហាន់ ឈឺពោះចង់បត់ជើងធំ ។ ដោយងងឹតផង ឈឺបួសាះផង អាឆៃវង្វេងស៊ុងនៅក្នុងភាពអន្ធការ មិនដឹងណាលិចណាកើត ។ អាឆៃវាទប់លែងបានហើយ វាដាច់ចិត្តស្រែកហៅលោកគ្រូវា ។

-លោកគ្រូរ៉ែត ជួយខ្ញុំ "កាណា" ផង លេចអាចម៍ដាក់ខោឥឡូវហើយ ។

អាឆៃនិយាយមិនទាន់ចប់ផង ស្រាប់តែឮព្រូស តែវាមានស្មារតីល្អ ប្រឹងយកដៃទាំងពីរទៅក្របួចជើងខោជាប់ ។ លោកគ្រូរ៉ែតគួសដែកកែសឆឹកៗ ស្រាប់តែឃើញអាឆៃនៅក្នុងភាពទាល់ច្រក បែរមុខទៅទល់ជញ្ជាំង ។ លោកគ្រូប្រឹងទៅបើកទ្វារ ។

-អាល្បល់យ (លោកគ្រូជេរ) អញប្រាប់តាំងពីក្បាលល្ងាចម្ល៉េះថាកុំឱ្យឯងផឹកទឹកត្នោតច្រើនពេកឯងមិនជឿអញ ។

អាឆៃប្រឹងក្របួចជើងខោទាំងពីរមែន ប៉ុន្តែវត្ថុរាវ ហូរតាមជើងខោ ប្រឡាក់ទាំងក្តារ ប្រឡាក់ទាំងជញ្ជាំងកុដិ ជះក្លិនស្អុយស្ទើរប្រកាច់ ។ ក្មេងក្មាន លោកនេន លោក "ភឹក " ផ្អើលឆោឡោ ស្មានតែភ្លើងឆេះកុដិ មិននិកស្មានថាអាឆៃរាគអាចម៍ ដាក់ខោសោះ ។ អាឆៃស្ទុះទៅដល់អណ្តូងខំលាងប្រាណវា ហើយគ្រវាត់ខោចោលនៅគុម្ពចេកបាត់ ។

វាខំរែកទឹក២០អំរែកមកលាងក្តារនិងជណ្តើរ តែទោះជាខំលាងយ៉ាងណា ក៏នៅតែធំក្លិនស្អុយ។ លោកគ្រូធំហួសចិត្ត អស់ពីខ្វាល់ទៅជាសើច ។

នៅវត្តថ្មគោលការរស់នៅជាមួយគ្នា(Cohabitation )រវាងលោកសង្ឃទាំងពីរគណ:(អែវម៉ែនិងអេវម៉េ) ចេះតែមានសភាពតានតឹងឡើងជាលំដាប់ ។ យប់មួយនោះ លោករគូអាចារយចៅខាងធម៌សម័យ លោកបាននិមន្ត ភិក្ខុ និងសាមណេរមកប្រជុំ ។

-" កាណា "(លោកគ្រូធំមានពុទ្ធដីកា) និមន្តអស់លោកមកប្រជុំនៅពេលនេះ ដើម្បីទូលថា ឧបាសក-ឧបាសិកាជើងវត្តទើបនឹងរកដីបានមួយដុំធំសំរាប់ធ្វើវត្ត ។ ដូចនេះ " កាណា" ចាត់លោកគ្រូអាចារ្យគ្រី និងអាចារ្យ ស្លួង ឱ្យនាំលោក"ភីក" និងនេនទៅរៀបចំកាប់ឆ្ការព្រៃទីនោះ រួចសង់កុដិជាបន្តបន្ទាប់ ។

## វត្តបឹងកុក

នៅខាងលិចទីក្រុងកំពង់ចាម គេឃើញមានបន្ទាយទាហានដ៏ធំៗពីរសង់នៅជាប់គ្នា គឺបន្ទាយទាហានជើង ក្រហម ( Canard osé pied rouge ) និងបន្ទាយទាហានជើងខ្មៅ ( Canard osé pied noir ) ។ មេបញ្ជាការខាង ទាហានជើងក្រហមជាបារាំង ចំណែកខាងជើងខ្មៅជាខ្មែរ ។ បើខ្ញុំមិនច្រឡំទេ ជំនាន់នោះគឺលោក ក្លួត- ប៊ុត ។ ទាហានទាំងពីរក្រុមនេះ ឈ្លោះកាប់ចាក់គ្នាគ្មានស្វាង ។ អភ័ព្វណាស់ខ្មែរយើង មិនដែលចេះសាមគ្គីគ្នាណាម្តងទេ តាំងតែពីដើមរហូតមក។ គ្រហស្ថឈ្លោះដោយគ្រហស្ថ បព្វជិតទៅដោយបព្វជិត ឆ្កែទៅដោយឆ្កែ ។

នៅជាប់និងបន្ទាយជើងខ្មៅ គេឃើញមានបឹងមួយយ៉ាងធំ បឹងនោះគឺបឹងកុក។ នៅលើផ្ទៃបឹងដ៏ល្វឹងល្វើយ គេឃើញមានបឿនដុះពាសពេញ ។ បឿនគឺជាការប្រជុំដោយតិណជាតិផ្សេងៗ មាន ត្រកួន កញ្ឆែត ត្រាវ កក់ ប្រាច់ ត្រកៀត កំប្លោក ។ល។ ដែលដុះតាន់តាប់ក្រាស់ ឃ្មឹក អណ្តែតលើទឹក ហើយដែលយើង អាចដើរជាន់ពីលើបាន ។ ក្រោមបឿនមានឫសដុះស្វែ គឺជាទីជំរកនៃត្រីទាំងឡាយ ។ ក្រៅពីជំរកនៃមច្ឆា បឹងកុកគឺជាអាងមួយយ៉ាងធំសំរាប់ ទទួលទឹកសំអុយ ដែលគេបង្ហូរមកពីបន្ទាយទាហានជើងខ្មៅ និងជើងក្រហម ។ បើសិនណាជាគ្មានទឹកថ្មីមកបន្ទាស់ ទឹកចាស់មួយឆ្នាំម្តងៗនោះ ទឹកនៅក្នុងបឹងនឹងក្លាយទៅជាទឹកសំអុយមិនខាន ។ នៅក្នុងរដូវវស្សា ទឹកក្នុងទន្លេមេគង្គ ឡើងយ៉ាងខ្លាំង ហើយហូរសង្សុកចូលទៅក្នុងបឹង យកទឹកថ្មីទៅបន្ទាស់ទឹកចាស់ ។

នៅខាងកើតបឹង គឺភូមិមេម៉ាយ ខាងលិចមានកន្លែងកប់ខ្មោចចិននិងដីទួលមួយយ៉ាងធំ ។ ដីទួលនោះហើយ ដែលឧបាសក-ឧបាសិកា ខាងលោកគ្រូអាចារ្យចៅប្រគេនទៅលោក ដើម្បីរៀបចំសង់វត្ត គឺវត្តបឹងកុកនោះឯង ។ ដី ទួលនោះធំទូលំទូលាយ តែមានស្មៅនិងដើមឈើដុះស៊ុបទ្រុប ត្រូវប្រើពេលយូរណាស់ដើម្បីកាប់ឆ្ការក្លូនឈើ ។

ជំនាន់នោះ អ្នកដែលទៅតាមលោកគ្រូអាចារ្យគ្រីនិងអាចារ្យស្លួង មាន១០អង្គ សិស្សបីនាក់ គឺខ្ញុំ អាឆៃ និង អាទិត ។ បើគិតជាលេខរៀង ខ្ញុំជាសិស្សលេខមួយ( numéro matricule : 1 ) នៅវត្តបឹងកុក លេខ២អាឆៃ លេខ៣ អាទិត ។

រៀងរាល់ព្រឹក មុនពេលព្រះអាទិត្យរះ លោកគ្រូអាចារ្យគ្រី និងអាចារ្យស្លួងតែងតែចាត់យើងទាំងអស់គ្នាទាំង បីនាក់ឱ្យ ទៅយកវេន (ពាក្យថាយកវេន គឺទៅយកម្ហូបអាហារនៅឯផ្ទះឧបាសក-ឧបាសិកាដែលត្រូវវេនធ្វើម្ហូប ប្រគេនលោក) នៅផ្សារកំពង់ចាម ភូមិមេម៉ាយ ដីដុះ ។ល។

ព្រះសង្ឃធ្វើដងរែកពីឫស្សីឱ្យយើងមួយម្នាក់ៗ ។ ដោយខ្ញុំតូចជាងគេ លោកឱ្យរែកតែចានស្រាក់ ពីបួនទៅប្រាំតែប៉ុណ្ណោះ ។ ចំណែកអាឆៃនិងអាទិត ពិ៧ទៅ៨ ។ មួយថ្ងៃៗឮតែវារអ៊ូ ព្រោះណាមួយវាធ្ងន់ ណាមួយវាឃ្លានបាយ ព្រោះពីព្រឹករហូតដល់ពេលលោកឆាន់បាយថ្ងៃត្រង់រួច ទើបបានបាយចូលពោះ ។

ព្រលឹមស្រាងៗ មិនទាន់បាត់ងុយដេកផង ពួកយើងត្រូវទៅបត់ជើង នៅមុខលោកដើម្បីទទួលបញ្ជា ។

-អាឆៃ( លោកគ្រូអាចារ្យគ្រីបញ្ជា)ឯងទៅយកវេននៅផ្ទះតាឈប់ អាទិតអ្នកស្រីតុប អាខៃអ្នកស្រីគង់ ។

ជំនាន់នោះ ខ្ញុំទៅយកវេនផ្ទះអ្នកស្រីគង់ សឹងរាល់ថ្ងៃ ។ គួរកត់សំគាល់ថា អ្នកស្រីគង់ជាម្តាយរបស់ "ឯកឧត្តម"(ពាក្យសីហនុ)ខៀវសំផន ។ គាត់ជាមនុស្សជឿបុណ្យបាបណាស់ ទៅសុំសីលរៀងរាល់ថ្ងៃសីល មិនសមបានកូនជាមេឃាតកររាស្ត្រខ្មែរសោះ ។ នេះពិតជាសំណើចចំអក នៃព្រហ្មលិខិតមែន ។

ថ្ងៃមួយនោះខ្ញុំទៅយកវេនជាមួយអាឆៃទៅផទះអ្នកស្រីតុប ឯភូមិមេម៉ាយ ។ ថ្ងៃត្រង់ហើយ ព្រះអាទិត្យបញ្ចេញចំហាយក្តៅយ៉ាងខ្លាំង ធ្វើឱ្យយើងបែកញើសជោកខ្លួន ។ ភូមិមេម៉ាយមិនសូវមានផ្ទះប៉ុន្មានទេ ហើយផ្ទះនីមួយៗនៅដាច់ពីគ្នាឆ្ងាយណាស់ ។ សងខាងផ្លូវគឺដើមត្រែង ។ អាឆៃនិងខ្ញុំរែកចានស្រាក់មកដល់កន្លែងស្ងាត់មួយ ស្រាប់តែខ្ញុំឃើញវាបើកគ្របចានស្រាក់ ។ ខ្ញុំមិនចាប់ភ្ញឹកព្រោះស្មានតែវាបើកមើលតាមធម្មតា ស្រាប់តែប៉ៃ អាឆៃលូកយកនំអាកោមួយមកពមផ្លប់ក្នុងមាត់ រួចហើយវាបើកចានស្រាក់មួយទៀត យកបាននំច័ក្កច័នមួយដុំទៀតមកស៊ីធ្វើវាហី ។

-យីអាឆៃ (ខ្ញុំស្រែក) ឯង "ម៉េច" បានជាហ៊ានស៊ី មុនលោកអញ្ចឹង? ឯងមុខជាចុះនរក ឯងមុខជាទៅជាក្អែក។ អាក្អែក! អាក្អែក!...

-"អាល្បល់យ" អញធ្វើតែអញ្ចឹងតាំងពីដើមមក ។ អាណាទ្រាំបាន តាំងពីព្រលឹម រហូតលោកឆាន់បាយរួចទើបបានបាយស៊ីនោះ ។ អាទិតក៏វាធ្វើតាមដូចអញដែរ ។ និយាយមិនទាន់បានចប់សព្វគ្រប់ផង អាឆៃបើកគ្របចានស្រាក់មួយទៀត លូកយកនំអាកោមួយមកញាត់មាត់ខ្ញុំផ្លប់ ។ រួចហើយវាយកដៃវាមកបបោសមាត់ខ្ញុំផ្អមៗ ព្រោះមានកំទេចដូងជាប់មាត់ ។ ធម្មតាគេតែងកោសដូងដាក់លើបង្អែម ហើយចានស្រាក់ដាក់បង្អែមនៅពីលើគេជានិច្ច ។

-អាភ្លើ (អាឆៃនិយាយ) អញបោសមាត់ឯងព្រោះមានកំទេចដូង បើឯងយកកំទេចដូងនេះទៅកុដិ លោកគ្រូពិតជាវាយឯងស្លាប់ ព្រោះលោកដឹងថាឯងលួចស៊ីនំ ។

ចាប់តាំងពីអាឆៃបំបួសខ្ញុំមក ខ្ញុំចេះលួចស៊ីរហូត ។ លួចស៊ីនៅភូមិមេម៉ាយ រួចហើយបន្តទៅទៀត នៅពេលមកដល់ត្រង់ផ្នូរខ្មោចចិន ។ ដោយរកល្បិចនេះឃើញ ខ្ញុំមានកម្លាំងរហូតឥតមានហេវហត់ដូចពីលើកមុនឡើយ ។

បួនប្រាំខែក្រោយមក ព្រះសង្ឃក៏សង់បានកុដិ បី-បួន និងវិហារឈើបណ្តោះអាសន្នមួយ ។ ព្រះសង្ឃទាំងអស់ ដែលគង់នៅវត្តថ្មគោល បូកទាំងក្មេងវត្ត ព្រមទាំងឆ្កែផងបាននិមន្តនិងនាំគ្នាមកនៅវត្តបឹងកុកជាស្ថាពរ ។ ម្តងនេះ អស់មាន "សង្គ្រាជ" ពីរទៀតហើយ ។

ដោយគ្មានទឹកម៉ាស៊ីននិងអណ្តូង ព្រះសង្ឃនិងក្មេងវត្ត នាំគ្នាប្រើប្រាសនិងមុជទឹកបឹងកុក ។ លុះមុជយូរៗទៅ ទាំងព្រះសង្ឃទាំងក្មេងវត្ត កើតចៃចេញពីខ្លួនរៀងៗខ្លួន ។ ចៃនោះខុសពីចៃចេញពីក្បាល គឺត្រង់វាមានពណ៌សចំឯណកឯចៃក្បាលវាមានពណ៌ខ្មៅ ។ ក្រៅពីកើតចៃ អាក្មេងវត្តធំៗ បែបព្រះសង្ឃផងមិនដឹង កើតស្រែងអង្គែបពេញពង ជាពិសេសអាឆៃវាស្មោគគ្រោកជាងគេ ។

ថ្ងៃមួយនោះ លោកគ្រូធំកោះហៅក្មេងមកប្រជុំ÷

- អាទិត ( លោកគ្រូធំមានពុទ្ធដីកា) អាជួន អាជ្រឹង អញនឹងបំបួសឯងក្នុងពេលឆាប់ៗនេះ ។ ចំណែកអាខៃអាឆៃ អាម៉ែន អញឱ្យឯងទៅរៀនសាលាបារាំង ព្រោះឯងដូចជាឆ្លាតជាងគេខាងរៀនអក្សរនិងគណិតសាស្ត្រ ។

ចាប់តាំងពីពេលនោះមក អាក្មេងវត្តចែកជាពីរពួក ក្មេងវត្តមួយផ្នែករៀនធម៌បួស មួយផ្នែកទៀតរៀនអក្សរបារាំង ។

នៅរដូវវស្សា ពេលភ្លៀងធ្លាក់ជោកជាំ ការធ្វើដំណើរពីបន្ទាយដើងខ្មៅទៅវត្តបឹងកុក ពិបាក ពីព្រោះផ្លូវសុទ្ធតែភក់ ហើយជាប់ជើងដូចយើងពាក់ "ប្រូដឺកាំង"(Brodequin ) ព្រោះជាដីឥដ្ឋ ។ បើជ្រុលតែដីភក់ជ្រៅបន្តិចច្បាស់ជាលើកជើងលែងរួច ស្អិតជាងតាំងម៉ែ ឬបាយម៉ានទៅទៀត ។ ដោយចង់ទាក់ទងឱ្យរាជការបារាំង ធ្វើផ្លូវធ្វើផ្លូវកៅស៊ូពីបន្ទាយដើងខ្មៅទៅវត្ត លោកគ្រូធំ បែកប្រាជ្ញាសង់សាលាបារាំងពីរបន្ទប់នៅក្នុងវត្ត ។ លុះសង់រួចហើយលោកក៏ប្រគល់សាលានោះទៅឱ្យក្រសួងសិក្សាធិការជាតិ ដោយសង្ឃឹមយ៉ាងមាំថា រាជការពិតជាជួយធ្វើផ្លូវសំរាប់ឱ្យសិស្សដើរបានស្រួលទៅកាន់សាលា ។ ដើម្បីសំរេចនូវគំរោងការនេះ លោកគ្រូធំបានចាត់ឱ្យលោកគ្រូរឿង អតីតចៅហ្វាយស្រុក ដែលចេះនិយាយភាសាបារាំងស្ទាត់ ទៅទាក់ទងនិងមេសាធារណការជាតិបារាំង(Conducteur des travaux publics ) ។ គួរកត់សំគាល់ថា វត្តបឹងកុក មានអតីតរាជការចំណាស់បីនាក់បានទៅសាងផ្នួស ព្រោះបើតាមពត៌មានថា លោកទាំងបី មានវិប្បដិសារីនៅក្នុងឆាកជីវិត ។ លោកសង្ឃទាំងបីអង្គនោះ គឺលោកតាប៊ុត ធ្លាប់ធ្វើគ្រូពេទ្យកាលនៅគ្រហស្ថ លោកតាស្បោង ធ្វើគិញ និងលោកតារឿងអតីតចៅហ្វាយស្រុក ។

ចៅហ្វាយស្រុករឿងកាលនៅធ្វើរាជការ លោកខិលណាស់ជាមួយនឹងស្រីៗ ។ ប្រពន្ធរបស់លោកអ្នកស្រីតុបកើតទុក្ខរីងរៃដោយសារតែរោគប្រច័ណ្ឌ ។ ថ្ងៃមួយនោះ អ្នកស្រីតុបមិននៅ លោកចៅហ្វាយស្រុកយើងយកសាហាយស្មន់មកធីងមោង( សុំទោស ព្រោះខ្ញុំប្រើពាក្យរបស់សម្តេចសីហនុ) នៅក្នុងផ្ទះ ។ ពេលដែលកំពុងជាប់ដៃប្រយុទ្ធស្វាប់រស់ ស្រាប់តែរបស់ម្យ៉ាងធ្លាក់ពីលើស្ពាកមកចំខ្នងលោកចៅហ្វាយស្រុកឮស្វូរទឹះ បណ្តាលឱ្យគាត់ភ្ញាក់ដូចគេចោលដាច់គ្នាទីងណាត់ទីងណែង ខ្លួនននលគកដូចសត្វជន្លេន ។

ប្រដាប់នៅបាញ់ត្រង់ធ្នូនៅឡើយ ។ មួយភ្លែតដំបូង លោកស្មានតែវត្ថុអីធ្លាក់មកលើ លោកមិននិកស្មានថាអ្នកស្រីតុបសម្ងំពួននៅលើស្ពាកសោះ ហើយទម្លាក់ខ្លួនមកលើលោក ។ ចាប់តាំងពីថ្ងៃនោះមក លោកចៅហ្វាយយើងស្រុករត់ចេញពីផ្ទះទៅចូលវត្តបឹងកុកទៅហោង ។

មួយខែក្រោយពីលោកគ្រូរឿងទៅទាក់ទងជាមួយអាជ្ញាធរខាងសាធារណការមក គេឃើញមានត្រាក់ទ័រពីរមកឈូសផ្លូវពីបន្ទាយដើងខ្មៅ ទៅដល់សាលារៀនវត្តបឹងកុក ។ សិស្សនិងគ្រូសប្បាយរីករាយជាខ្លាំង ព្រោះបានផ្លូវដើរមិនសូវជាប់ភក់ ។ សាលានោះមានពីរថ្នាក់ គឺឧត្តមដ្ឋាន ក និងខ (Cours supérieurs A & B ) ដំបូលប្រក់ស្បូវជញ្ជាំងធ្វើអំពីដីឥដ្ឋ លាយចំបើងអាចម៍គោនិងបន្ទះឫស្សី ។ អាយុមិនបានពីរឆ្នាំផង សាលានោះទ្រុឌទ្រោមចង់រលំទៅហើយ ។ នៅតាមជញ្ជាំង គេឃើញបន្ទះឫស្សីលេចចេញពីដីឥដ្ឋឱ្យរពុយ មិនខុសពីរនាំងព្រួលឡើយ ។ ចំណែកនៅតាមសសរគេឃើញសុទ្ធតែហ្វូងកណ្តៀរ ។ បើសិនជាមានខ្យល់ព្យុះធំ សាលានេះច្បាស់ជាបាក់សង្កត់ទាំងសិស្សទាំងគ្រូមិនខាន ។

អាឆៃនិងខ្ញុំ រៀននៅថ្នាក់ឧត្តមដ្ឋាន "ខ"(Cours supérieur B) ជាមួយគ្នា ហើយអង្គុយជាប់គ្នាថែមទៀត ។ អាឆៃបងខ្ញុំយ៉ាងតិច៥ឆ្នាំ តែខ្ញុំហៅវាសឹងដាច់សាច់ តែវាមិនថាអីដែរ។ លោកគ្រូខ្ញុំ ឈ្មោះលោកគ្រូឆែប ចំណែកលោកគ្រូថ្នាក់ឧត្តមដ្ឋាន "ក"(Cours supérieur A) ឈ្មោះលោកគ្រូយក្ខ ។ មែនទែនលោកគ្រូទាំងពីរមិនមែនឈ្មោះយក្ខនិងឆែបនោះទេ តែដោយម្នាក់មាឌធំ ម្នាក់ទៀតឆែបមាត់ ទើបសិស្សវាឱ្យឈ្មោះយក្ខនិងឆែប ទៅ ។ គាត់ទាំងពីរមិនដឹងទាល់តែសោះ ថាឈ្មោះក្រៅគាត់គឺ យក្ខនិងឆែប ។ គ្រូទាំងពីរនាក់នេះកាចសាហាវណាស់ វាយសិស្សឥតត្រាប្រណី ។ សិស្សម្នាក់ៗ មានរបួស ទុកឱ្យកូនមើលគ្រប់ៗគ្នា ។ ខ្ញុំរបួសដៃស្តាំ មានសម្លាករហូតដល់សព្វថ្ងៃ ។ នៅពេលឮសម្លេងផ្តៅខាងលោកគ្រូយក្ខ លោកគ្រូឆែបចាប់រករឿងសិស្សភ្លាម ។ មួយថ្ងៃៗ ឮសូរតែសម្លេងផ្តៅឆ្លើយឆ្លងគ្នា ដូចសម្លេងដូរ្យតន្ត្រី ។ នៅខាងលោកគ្រូឆែប សិស្សដែលមានអាយុជាង២០ឆ្នាំប្រហែល១០នាក់ ។ លោកគ្រូឆែបនិងយក្ខបង្គាប់ឱ្យសិស្សម្នាក់ៗរកផ្តៅឱ្យគាត់ម្នាក់មួយ ក្នុងមួយអាទិត្យ សិស្សណាមិនបានផ្តៅត្រូវទោសយ៉ាងតិច

១០រំពាត់ ។ បើកាលណាគេដើរចូលទៅក្នុងថ្នាក់ មុនដំបូងគេឃើញក្តារខៀនពីរ រួចហើយរំពាត់ផ្តៅ មួយបាច់យ៉ាងធំ នៅក្រោយក្តារខៀន ។ សិស្សម្នាក់ៗខ្លាចលោកគ្រូជាងខ្លាចខ្លា តែពាក្យចាស់លោកថា គ្រូកាចសិស្សខូច ។

ថ្ងៃមួយនោះពួកអាធំៗ ជំនុំគ្នា ដើម្បីរកមធ្យោបាយទប់ទល់នឹងផ្តៅដែលស្វិតពេក លោកគ្រូវាយវាមិនបាក់សោះ ។ អាឃិនក្បាលកញ្ជាស់ជាងគោ(អាយុប្រហែល២៣) ឱ្យយោបល់÷

-បើតាមអញដឹងមានតែទឹកនោមទេ ទើបធ្វើឱ្យផ្តៅស្រួយ ។ ឯងទាំងអស់គ្នា នាំគ្នានោមដាក់បំពង់ឫស្សី រួចហើយថ្ងៃព្រហស្បតិ ឬអាទិត្យ យើងយកទឹកនោមទៅស្រោចលើផ្តៅ យកវាទៅហាលថ្ងៃ ។ ផ្តៅពិតជាស្រួយ ។

ចាប់តាំងពីពេលនោះមក គ្រូឆែបវាត់សិស្សមួយឆ្វាប់ ផ្តៅបាក់ប្រាវ! មួយឆ្វាប់បាក់ប្រាវ! ។ ក្នុងមួយថ្ងៃអស់ផ្តៅមួយបាច់ធំ ។ លុះដល់អស់ផ្តៅ គាត់ស្ទុះទៅកន្ត្រាក់បន្ទះឫស្សី ដែលលេចចេញពីជញ្ជាំង ជីឥដ្ឋ មកវាយសិស្សគ្មានត្រាប្រណី ។ ម្តងនោះ មិនដឹងជាចៃដន្យអី នៅពេលដែលគាត់កន្ត្រាក់បន្ទះឫស្សីមកវាយសិស្ស ឫស្សីមុតដៃគាត់ចេញឈាម៉ាវ ។ អាសិស្សបែបវាសប្បាយចិត្តពេកក៏មិនដឹង ស្រាប់តែផ្ទុះសំណើចគ្រប់គ្នា ។ គ្រូឆែបមុខឡើងស្លាំងចាប់វាយសិស្សបន្តទៅទៀត ដូចឆ្កែឆ្កួត ។ ដោយឃើញផ្តៅនោះចេះតែបាក់ ហើយបែបខ្លាចមុតដៃនឹងបន្ទះឫស្សីទៀត គ្រូឆែបដូរមធ្យោបាយ ដោយប្រើជន្ទួញម្តង ។ គាត់ចាក់សិស្សដូចចាក់គោ ជាពិសេសធ្វើបាបពួកអាធំៗ ព្រោះវាស្ពឹក ហើយរៀនអន់ជាងអាតូចៗ ។ គ្រូឆែបវាយសិស្សខ្លាំង នៅពេលសរសេរតាមអាន បារាំង ( Dictée française )ជាពិសេស accord du participe passé employé avec l'auxiliaire avoir ។ នៅពេលសរសេរតាមអានម្តងៗ អាឆៃភ័យមុខឡើងស្លាំង ព្រោះគ្រូចេះតែដើរមកខ្វិលៗពីក្រោយខ្នងវា ។

នៅជំនាន់នោះសិស្សប្រើស្លាបប៉ាកាដែលមានដងធ្វើអំពីឈើ ហើយស្លាបវាធ្វើអំពីដែក ។ សិស្សអាចដកស្លាបប៉ាកាផ្លាស់ប្តូរបាន នៅពេលដែលវាសឹក ឬចាស់គ៌រិលពេក ។ នៅលើតុសិស្ស គេឃើញមានដបទឹកខ្មៅម្នាក់មួយៗ ។

បើនិយាយពីស្លាបប៉ាកាអាឆៃវិញ ឡើងក្រាំងដោយសារទឹកខ្មៅរុំព័ទ្ធ ហើយវាមិនដែលដូរសោះ ។ ថ្ងៃមួយនោះជាថ្ងៃសរសេរតាមអានបារាំង ។ អត្ថបទនោះ ខ្ញុំនៅចាំទាល់ឥឡូវនេះ គឺ( la pagode de mon village ) វត្តនៅភូមិខ្ញុំ ។ នៅពេលចាប់ផ្តើម លោកគ្រូឆែប មិនដឹងជាចៃដន្យអី គាត់មកច្រត់ដៃក្បែរអាឆៃ ។ លោកគ្រូចាប់អានសិស្សចាប់សរសេរ ( Entourée d'une importance haie de koki, la pagode se laisse apercevoir de loin son toit de tuiles rouges..) ។ អាឆៃ ដោយវាភ័យនឹងជន្ទួញលោកគ្រូឆែបពេក ស្រាប់តែនិយាយ ចេញខ្លួនឯង ដោយលោកគ្រូឥតទាន់សួរផង ថា÷

- បានជាគេសរសេរ (Entourée )é accentaigu e ពីព្រោះ sujet ប្រធានវា La pagode ។ រួចហើយមិនដឹងជាវារញីរញ័រដូចម្តេចទេ ស្រាប់តែវាយកស្លាបប៉ាកា ទៅចាក់ដៃគ្រូឆែប ដែលច្រត់នៅលើតុវាឮស្នូរឈឹប ។ លោកគ្រូភ្ញាក់ផង បែបឈឺផង ស្រែកឮសូរអ្ហូយ! រត់ទៅអង្គុយចេញទឹកភ្នែកនៅមាត់ទ្វារថ្នាក់ ។ ថ្ងៃនោះលោកគ្រូឆែបវាយអាឆៃទាល់តែរាគនោម ។ តែចាប់ពីនោះមកដែរ អាឆៃបានសុខរហូតព្រោះគ្រូឆែបបែបញញើតអាឆៃ មិនសូវហ៊ានមកក្បែរវាទៀតទេ ។

ថ្ងៃមួយនោះជាថ្ងៃច័ន្ទ ក្រោយពីឮស្នូរជួង សិស្សនាំគ្នាឈរជាពីរជួរនៅមុខថ្នាក់ចាំស្តាប់បញ្ជាគ្រូ ។ ក្រោយពីសិស្សចូលថ្នាក់អង្គុយស្រួលបួលហើយ លោកគ្រូឆែបក៏ដើរ ទៅកាន់តុរបស់គាត់ ហើយដាក់គូទនៅលើកៅអីឈើយ៉ាងស្រួល ។ គាត់បើកថតតុខ្វាក ស្រាប់តែរំពេចនោះគាត់ផ្ងារខ្លួនទៅក្រោយ ស្ទុះរត់ចេញពីតុយ៉ាងប្រញាប់ ស្រែកទៅកាន់សិស្សថា÷

- អាចង្រៃណាជុះអាចម៍ដាក់ថតតុ?

មុខគាត់ឡើងក្រហមដូចល័ខ ។ គាត់ដេញសិស្សចេញពីថ្នាក់ ម្នាក់ៗមុខឡើងស្លាំង ។

-តុណាត្រូវវេនបោសថ្នាក់ថ្ងៃហ្នឹង?

-តុទី១ លោកគ្រូ(អាយិនឆ្លើយ)

-បើអញ្ចឹង (លោកគ្រូបង្គាប់) ពួកអាតុទី១ យក ថតតុទៅលាង ។

ចំជាស៊យមែន អាតុទី១ គឺខ្ញុំនិងអាឆៃ ។ ខ្ញុំនិងអាឆៃ នាំគ្នាទៅសែងថតតុចេញទៅក្រៅ ។ ម៉ែអើយ! អាចម៍អីក៏ស្អុយម្ល៉េះ ស្អុយខ្ទោះតែម្ដង គឺស្អុយជាងអាចម៍អាឆៃកាលវាលេចអាចម៍ដាក់ខោ កាលពីវានៅវត្តថ្មគោល ។ អាចម៍នេះបានជាស្អុយប្លែក មកពីអាអ្នកជុះដាក់ថតតុ ជុះតាំងពីល្ងាចថ្ងៃសៅម្ល៉េះ ។ ដូចនេះ ល្មមដល់ថ្ងៃច័ន្ទ ពីរយប់មួយថ្ងៃឯណោះ ។ ថ្ងៃនោះឯង មិនខុសពីថ្ងៃលេង"សៀក"(Cirque)ទេ គឺអស់ពីវាយសិស្សនៅក្នុងថ្នាក់ហើយ គ្រូឆែបដេញសិស្សចេញ ពីថ្នាក់ ឱ្យទៅលុតជង្គង់ នៅកណ្ដាលថ្ងៃក្ដៅទៀត ។ គាត់ធ្វើបាបសិស្សចង់ស្លាប់ តែមួយអាទិត្យក្រោយមកគ្រូឆែបដូចស្លូតច្រើន ។

ក្រោយមកខ្ញុំដឹងថា អ្នកដែលជុះអាចម៍ ដាក់ថតតុគ្រូ គឺអាឆៃហ្នឹងតែម្ដង ព្រោះវាសារភាពនៅពេលវិស្សមកាលធំបែកពីគ្រូឆែប ។ ទេវតាមិនជួយ ត្រូវវានិងខ្ញុំខំលាងអាចម៍ស្អុយស្ទើរប្រកាច់ ។ ខ្ញុំប្រទេចផ្ដាសាវាបីថ្ងៃ បីយប់ ។

-"វ៉េង" មិនឱ្យអញ(អាឆៃនិយាយមកកាន់ខ្ញុំ) ធ្វើអញ្ចឹង "ម៉េច" នឹងកើត បើគាត់សាហាវដូចខ្លាអញ្ចឹងនោះ ។

រៀនដល់ថ្នាក់ឧត្ដមដ្ឋាន អាឆៃមានអាកប្បកិរិយាផ្លាស់ប្ដូរច្រើនណាស់ ។ ព្រះសង្ឃក៏លែងឱ្យវាទៅយកវេននៅថ្ងៃព្រហស្បតិ ឬអាទិត្យ ព្រោះលោកយល់ថាវាធំណាស់ទៅហើយ ។ មួយថ្ងៃៗ ខ្ញុំឃើញវាឆ្លុះកញ្ចក់ ផ្អៀងផ្អងមើលជងខ្លួន និងសិតសក់យ៉ាងតិច២០លើក ។ វាសិតសក់ "បូកគោ"(ជាម៉ូដជំនាន់នោះ)រុញឡើងទៅលើកំប៉ូកៗដូចបូកគោ ហើយយកប្រេងប្រីយ៉ង់ទីន(Brillantine) មកលាបសក់កុំឱ្យវារសាត់ ឬធ្លាក់មករប៉ាត់រប៉ាយ ។

ថ្ងៃមួយនោះ វាទៅនិយាយប្រាប់ម៉ែឪវាថា វាជិតប្រឡងចូលវិទ្យាល័យហើយ ហើយគ្រូបង្គាប់ឱ្យទិញកង់"គួស"(Course) ខោបារាំង ព្រមទាំងស្បែកជើង"អង់ប្រង់"តាមពិតគឺ "en France" តែខ្មែរយើងអានមិនច្បាស់ នាំគ្នាថា"អង់ប្រង់"ៗទៅ ។ ដោយសារចាញ់ "ប្រូ" អាឆៃ ម៉ែឪវាទៅលក់ស្រែអំពកអស់ពីរ-បី ដើម្បីទិញរបស់ខាងលើឱ្យវា ។ គួរឱ្យអាណិតអាសូរម៉ែឪអាឆៃណាស់ ហេតុតែគាត់ចង់ឱ្យកូន ចូលវិទ្យាល័យក្រែងបានធ្វើថៅកុង គ្រាន់នឹងបានស៊ីសំណូកដូចគេ ព្រោះធ្វើស្រែវានឿយពេក ។

ពេលវេលាកន្លងទៅជាលំដាប់ អាឆៃកាន់តែមានចិត្តរវើរវាយ ខ្លាំងឡើងៗ ។ ល្ងាចមួយនោះ ខ្ញុំឃើញវាដេញ "ម៉ង់ដូលីន" (Mandoline) នៅលើកុដិ ព្រោះលោកគ្រូធំ និង ភិក្ខុឯទៀតនិមន្តទៅសូត្រមន្តឯភូមិមេម៉ាយ សល់តែលោកទិតនៅចាំកុដិ ។ ទិត-ឆៃ-ខៃ សុទ្ធតែមិត្តភក្តិដ៏ជិតដិត ខុសតែទិតទៅជាតំណាងព្រះពុទ្ធប៉ុណ្ណោះ ។ ប៉ុន្តែយើងទាំងបីនាក់ នៅតែលេចលើស្មើក្រោមដដែល ។ អាឆៃអ្នកដេញ ម៉ង់ដូលីន លោកទិតអ្នកច្រៀង៖ "ឱផ្កាណាត្រីរីកក្បោះក្បាយ..." បន្ទាប់មកទៀត៖ "ព្រះពាយផាយផាត់ បក់ផាត់ឆ្លងមកយប់ជ្រៅ ចុងស្រល់អែនទៅ ទោរតាមខ្យល់..." ចុងទីបញ្ចប់គឺបទឆ្មាខ្មៅ៖ "គេងថ្ងៃលេងលក់ទៅឃើញឆ្មាខ្មៅធំមួយ..." ។ ជំនាន់នោះបទទាំងបីនេះ៖ ឆ្មាខ្មៅ ផ្កាណាត្រី និងចុងស្រល់ ជាបទដែលគេតែងតែនិយមច្រៀងនៅគ្រប់ទីកន្លែងក្នុងស្រុកខ្មែរ ។

ក្រោយពីច្រៀងហើយបែបហត់ក៏មិនដឹង លោកទិតប្រើខ្ញុំឱ្យទៅយកកំសៀវ ទឹកដែលលោកដាំទុកមួយស្របក់ធំហើយ ។ នៅពេលខ្ញុំយកកំសៀវទឹកមកដល់ លោកទិតក៏ស្ទុះទៅយកចានស្លាបព្រា ។ មុនដំបូងខ្ញុំឆ្ងល់ ជាខ្លាំង ថាហេតុដូចម្ដេច បានជាលោកទិតក៏ស្ទុះទៅយកចានស្លាបព្រា មិនយកកែវមកវិញ ។ លោកទិតចាក់ទឹកកំសៀវទៅក្នុងចាន តែទឹកមានពណ៌ស ហើយហូរយឺតៗ ហាក់ដូចជាយើងស្ទះនោម ។ លោកទិតបើកគំរប កំសៀវខ្វាក ។ ពេលនោះទើបខ្ញុំដឹងថា លោកទិតមិនមែនដាំទឹកតែទេ គឺដាំបបរ ។ ខ្ញុំស្រែកឡូឡា៖

"យីលោកទិត ម៉េចក៏ដាំបបរអញ្ចឹង... លោកសង្ឃណាឆាន់បបរពេលយប់ ។ ចាំមើល កាណាទូលលោកគ្រូធំហើយ! ។

-ឯងមិនឱ្យអញស៊ីយ៉ាងម៉េច បើអញឃ្លានចង់ស្លាប់ ។

អាឆៃ មានហិបឈើមួយយ៉ាងធំ សំរាប់ដាក់ខោអាវ និងសៀវភៅ ។ ថ្ងៃមួយមិនដឹងជាចៃដន្យអី អាឆៃវាភ្លេចបិទហិប ខ្ញុំក្រឡេកទៅក្នុងហិប ឃើញសំបុត្រមួយគំនរ ។ ខ្ញុំរពិសដៃក៏ស្ទុះទៅយកសំបុត្រនោះមកមើល ។ ស្រាប់តែប៉ៃ គឺសុទ្ធតែសំបុត្រស្នេហា ដែលអាឆៃសរសេរទុកជាយូរខែណាស់មកហើយ ហើយមិនចេះបានផ្ញើសោះ ។ សំបុត្រទាំងអស់ប្រហែល១០ ។ ខ្ញុំបើកសំបុត្រទី១មើល៖

-មកដល់អូនចាន់ធូ!

" ជាបឋមសូមអូនអភ័យទោស ព្រោះតាំងពីបងបានឃើញ និងស្គាល់អូនមក បេះដូងបងរបស់បងដើរខុសចង្វាក់រៀងរាល់ថ្ងៃ..."

ហត្ថលេខា

ហុង-វ៉ាន់ឆៃ

ខ្ញុំយកសំបុត្រទី២ មកមើលទៀត៖

"...ម្ចាស់ស្នេហ៍បងអើយ បើបងមិនបានឃើញដំបូលផ្ទះអូនទេ បងពិតជាបាយមិនបាន អែងមិនលក់ ។ សូមអូនមេត្តាបងផង ..."

ខ្ញុំអានទាល់តែអស់សំបុត្រអាឆៃ អានផងសើចផង សើចស្ទើរចុកពោះ ព្រោះសេចក្តីក្នុងសំបុត្រ មើលទៅពិតជាទប់សំណើចមិនបានឡើយ ។

នៅពេលដែលខ្ញុំអានសំបុត្រចប់ អាឆៃមកដល់ល្មម ។

- យី (អាខៃ) អា" ល្បល់យ" ម៉េចលួចមើលសំបុត្រអញអញ្ចឹង?

- អាឆៃ ឯងចាំបាច់លាក់នឹងអញធ្វើអី គ្រាន់តែរឿងស្នេហាអញ្ចឹងនោះ ។ ម៉េចឯងសរសេរសំបុត្រទុកមួយគំនរមិនព្រមផ្ញើ ? ។

- មកពីអញ(អាឆៃតប) មើលទៅដូចជាមិនពិរោះសោះអាំ ។

- បើអញ្ចឹងចាំអញជួយសរសេរម្តង ។ អញសរសេរជាកំណាព្យវិញ ។

- មែនអាំ ( អាឆៃ) យោបល់ឯងល្អ ព្រោះឯងពូកែជាងអញឆ្ងាយណាស់ខាងតែងសេចក្តីនិងកំណាព្យកាព្យឃ្លោង ។

ខ្ញុំចាប់ផ្តើម៖

" មកដល់អូនចាន់ធូម្ចាស់ស្នេហ៍

" អូនអើយខ្លួនបងដូចទន្សាយភ្លើ ដែលចង់បានច័ន្ទនៅស្ថានលើ មិនសមមកផ្សង..."

ហត្ថលេខា

ហុង-វ៉ាន់ឆៃ

បុរសកំសត់

អាឆៃយកកំណាព្យខ្ញុំមកអានបីបួនដង ។ វាសរសើរខ្ញុំមិនដាច់មាត់៖

- ល្អមែនៗ អញពិតជាផ្ញើទៅនាងហើយម្តងហ្នឹង! ។

ជីតាអឆៃឈ្មោះហុង ។ នៅសាលាឈ្មោះវាពិតប្រាកដគឺ ហុង-វ៉ាន់ឆៃ ។ ឈ្មោះសំឡាញ់ខ្ញុំពីរោះណាស់ សមតែឈ្មោះតួឯក កុន ។ ដោយសារតែអាឆៃកើតរោគស្នេហា អញ្ចឹងហើយបានជាវាទៅបោកម៉ែឪវា ឱ្យគាត់ទិញកង់ ខោអាវ ស្បែកជើង ។ ហើយមួយថ្ងៃៗ ផ្សៀងផ្សងៗនៅតែមុខកញ្ចក់ ។ វាខំរៀនដេញ " ម៉ង់ដូលីន " ដើម្បីបណ្តែតអារម្មណ៍ទៅតាមចង្វាក់ភ្លេង ។

នាងចាន់ធូ រៀននៅថ្នាក់មធ្យមដ្ឋានទី២ (Cours moyen 2ème année ) ជាកូនថៅកែរ៉ឺម៉ក ( Remorque ) នៅក្បែរបន្ទាយជើងខ្មៅ ។ អាឆៃស្គាល់នាងដោយសារ វាធ្លាប់ទៅយកវេន នៅផ្ទះនាងជាញឹកញយណាស់ ។ ឪពុកនាងឈ្មោះតន ម្ដាយឈ្មោះឈន ។ ថៅកែស្រីនេះឆ្នាស់ដូចអង្រ្គងភ្លើង ។ ថៅកែតនខ្លាចប្រពន្ធ ជាងខ្លាចម៉ែឪគាត់ទៅទៀត ។ នាងចាន់ធូមានបងប្រុសមួយរៀននៅថ្នាក់ទី៥ នៅវិទ្យាល័យព្រះសីហនុ ជាប់នឹងបន្ទាយជើងក្រហម ។

នៅពេលទៅយកវេននៅផ្ទះថៅតនម្ដងៗ អាឆៃតែងតែជួយជួសជុលរ៉ឺម៉កគាត់ ។ ថៅកែយើងពេញចិត្តនឹងអាឆៃណាស់ ព្រោះវាពូកែខាងជួសជុលម៉ាស៊ីន ហើយឆាប់យល់ការទៀត ។ នាងចាន់ធូស្គាល់អាឆៃច្បាស់ណាស់ ព្រោះជួនកាលថៅកែតនឃាត់វាឱ្យនៅស៊ីបាយជាមួយគាត់ ក្រោយពីជួសជុលរ៉ឺម៉កហើយ ។ រៀងរាល់អាទិត្យ ឬថ្ងៃបុណ្យវាតែងតែដើរទៅក្រវែលផ្ទះនាងចាន់ធូ មិនខុសពីចោរដើរក្រឡឹងមើលផ្ទះនរណាម្នាក់មុននឹងចូលទៅលួចនៅពេលរាត្រី ។

យប់មួយនោះខែភ្លឺថ្លាល្អណាស់ ។ អាឆៃចេញបាត់ពីកុដិ ខ្ញុំចេះតែសួរខ្លួនឯងថា តើអាឆៃវាទៅណា? ។ បន្តិចក្រោយមកស្រាប់តែឃើញវាលេចមកដល់កុដិ ដកដង្ហើមស្ទើរមិនដល់គ្នា យួរស្បែកជើងម្ខាងនៅដៃស្ដាំ ។

-វាម្ដេចទៅហើយអាឆៃ?(ខ្ញុំសួរ)

-អញវិសតែកុនអាសម្លាញ់ ព្រោះបងនាងចាន់ធូដេញអញប្រកិតៗ។

-បើអញ្ចឹងមានតែឯងទៅលបនាង?

-អញមិនមែនទៅលបនាងទេ អញទៅជួបនាង ព្រោះចាន់ធូឱ្យអញទៅជួប តែវាស៊យដោយបងនាងឃើញ ។

-ចុះស្បែកជើងមួយចំហៀងទៀត ទៅឯណាទៅ? (ខ្ញុំសួរ)

-មិនដឹងជ្រុះនៅត្រង់ណាទេ ព្រោះអញប្រាស់យកយករួចខ្លួនមួយគ្រាសិន ។

ដោយសាររឿងស្នេហា អាឆៃប្រឡងធ្លាក់មិនបានចូលវិទ្យាល័យព្រះសីហនុនឹងគេទេ ក្រោយមកអាឆៃរកបានការធ្វើនៅចំការកៅស៊ូជប់ ក្បែរស្រុកសួង ។ ហេតុតែគូព្រេងពីអតីត អាឆៃបានរៀបការជាមួយនាងចាន់ធូទៅ ។ ក្រោយពីការរួច ថៅកែតនឱ្យវាឈប់ធ្វើការ ទៅជួយរកស៊ីគាត់ ។ អាឆៃតស៊ូហើយចិត្តធ្ងន់ណាស់ ព្រោះម្ដាយក្មេកវាឆ្នាស់ពេកកន្លង កូនមានប្ដីហើយនៅតែវាយប្រដៅដូចកូនក្មេង ។ មិនត្រឹមតែវាយតែនាងចាន់ធូទេ ជួនកាលគាត់វាយដល់អាឆៃរត់ចេញពីផ្ទះតែខោខ្លីមួយចង្កេះ ។ មួយសន្ទុះធំក្រោយមក នៅពេលម្ដាយបាត់ខឹង ទើបនាងចាន់ធូដើរទៅរកប្ដីឱ្យមកផ្ទះវិញ ។ គួរឱ្យអាណិតអាឆៃណាស់ ប៉ុន្តែបិនដឹងធ្វើដូចម្ដេចទេ ព្រោះព្រហ្មលិខិតចារមកអញ្ចឹងទៅហើយ ។

២០ឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៣ ក្រោយពេលដែលពួកអាបីសាចខ្មែរក្រហមវាយខេត្តកំពង់ចាម អាឆៃក៏នាំគ្រួសារព្រមទាំងឪពុកម្ដាយក្មេកវាមកនៅភ្នំពេញ ក្បែរពេទ្យលោកសង្ឃ មិនឆ្ងាយប៉ុន្មានពីផ្ទះខ្ញុំទេ ។វាមានកូន៤នាក់ហើយ រកស៊ីលក់សាំង ។ ជីវភាពគ្រួសារអាឆៃធូរធាណាស់ តែម្ដាយក្មេកវានៅតែកាចដដែល គឺកាចជាងកាលពីនៅកំពង់ចាមទៅទៀត ។អាឆៃខ្លាចម្ដាយក្មេក ។ ប្រពន្ធវាអាណិតប្ដីសើរខ្លោចចិត្ត តែមិនដឹងធ្វើដូចម្ដេច ព្រោះខ្លួនឯងក៏ខ្លាចម្ដាយដែរ ។ នៅពេលខ្ញុំទៅលេងវាម្ដងៗ ម្ដាយក្មេកវា ប្រពន្ធវាសប្បាយចិត្តបាស់ ព្រោះខ្ញុំបានកំដរបរិយាកាស និងរៀបរាប់ពីអនុស្សាវរីយ៍ចាស់កាលនៅវត្តបឹងកុក ។ ប្រពន្ធវាតែងតែខ្សឹបដាក់ត្រចៀកខ្ញុំថា សុំឱ្យខ្ញុំមកលេងឱ្យបានញឹកញាប់បន្តិច ព្រោះបើមានវត្តមានខ្ញុំ មីងឈនគាត់ស្លូតណាស់ មិនរករឿងអាឆៃ ប្ដីនាងឡើយ ។ មីងឈននេះពិតជាកប៉ាល់ភ្លើងមែន ឱ្យតែមានរឿងមិនពេញចិត្ត គាត់រករឿងអាឆៃ ឬប្រពន្ធវាភ្លាម។

ថ្ងៃ១៧មេសា១៩៧៥ ពួកអាទមិឡចូលដល់ក្រុងភ្នំពេញ ។ វាដេញប្រជាជនចេញពីទីក្រុងភ្នំពេញ ។ អាឆៃព្រមទាំងគ្រួសារ បើកឡានមករកខ្ញុំជាបន្ទាន់ យើងទាំងពីរគ្រួសារក៏នាំគ្នាធ្វើដំណើរចេញពីទីក្រុងទាំងអស់គ្នា ។

យើងនាំគ្នាដើរតាមមាត់ទន្លេ សំដៅទៅទីក្រុងកំពង់ចាម ។ អស់រយៈពេលពីខែ ទើបទៅដល់ស្រុកស្ទួង ។ មកដល់ស្រុកស្ទួង ពួកទមិឡក៏ដឹកយើងទាំងពីរគ្រួសារឱ្យមកនៅភូមិថ្នល់ ស្រុក តំបែ គោកស្រុក ក្នុងខេត្តកំពង់ចាម ។

មកដល់ភូមិថ្នល់ ពួកទមិឡ ឥតសាសនា ឱ្យយើងសង់រោងពីរ រោងមួយនៅខាងកើតភូមិ រោងមួយនៅខាងលិចភូមិ ។ អាឆៃនៅ "វាំង" (ជាពាក្យសើចលេងជាមួយអាឆៃ) ខាងលិច.... ខ្ញុំនៅ "វាំង" ខាងកើត ។ រោងឫស្សីនីមួយៗប្រវែងប្រហែល៣០ម. បើប្រសិនណាជាអ្នកណាមួយហ៊ានប្រតិបត្តការសឹកនៅពេលយប់ ច្បាស់ជាឆ្កើគ្មាននរណាដេកពួនបានឡើយ ។ អាឆៃដោយសារធ្វើការហេវហត់ពេក វាមិនបានបំរើឪពុកម្តាយក្មេក ដូចកាលនៅសង្គមចាស់ទេ ។ តែមកដល់រោងវាលូនចូលដេកតែម្តង ។ ម្តាយក្មេកវា ជាមនុស្សចិត្តអាក្រក់ណាស់ ជេរកូនប្រសារមិនស្វាង ។ ណាមួយហេវហត់ ណាមួយឥតមានបាយស៊ី អាឆៃមួម៉ៅហ៊ានឆ្លើយតបនឹងម្តាយក្មេក ។ ចាប់តាំពីអាឆៃតមាត់គាត់ គាត់ប្រមូលមាសពេជ្រពីប្រពនធវាមកទុកខ្លួនឯង ។ បែបខ្លាចអាឆៃយកមាសទៅដូរអង្ករពួកទមិឡក៏មិនដឹង ។ ល្ងាចមួយនោះ អាឆៃមកដល់រោងយប់ងងឹត ខ្លាំងណាស់ទៅហើយ វាក៏យកទឹកមួយថាំង ដែលរបពន្ធវារែកទុកឱ្យម៉ែមកងូត ។ កំពុងលាបខ្លួនម្តាយក្មេកវាជេរបញ្ឆោថា អាឆៃឥឡូវដល់ថ្នាក់ងូតទឹកក្នុងផ្ទះហើយ ។ ចាប់តាំងពីថ្ងៃនោះមក អាឆៃចូលវាំង ខាងលិចលែងបាន ព្រោះម្តាយក្មេកវាជេរមិនស្វាង ហើយបង្គាប់ឱ្យកូនគាត់លែងប្តីថែមទៀត ។ វារត់ទៅវាំងឯកើតជាមួយខ្ញុំ ។ ថ្ងៃមួយអង្គការ ចាត់ឱ្យអាឆៃទៅលើកទំនប់ ស្រាប់តែឃើញឡាន "កាមីញ៉ុង" ពីរបើកចូលមកក្នុងភូមិ ។ ពួកទមិឡពីរ-បីនាក់កាំភ្លើងនៅដៃ ដើរទៅប្រមូលពួករោងខាងលិច មកឡើងឡានព្រោះអង្គការត្រូវលើកទិសថ្មី ។ ប្រពន្ធអាឆៃទឹកភ្នែករលីងរលោង ស្រែកអង្វរពួកអាបីសាច សុំនៅភូមិថ្នល់តទៅទៀតព្រោះប្តីគាត់ទៅលើកទំនប់មិនទាន់មកផង ។

-តែអង្គការលើកទិសហើយ(អាទមិឡម្នាក់និយាយ) គ្មាននរណាជំទាស់បានទេ ។ ភ្លាមឡើងៗ ។

ប្រពន្ធអាឆៃ កូនរបស់វា ព្រមទាំងឪពុកម្តាយក្មេក នាំគ្នាឡើងលើឡានទាំងទឹកភ្នែក ។ គ្មាននរណាម្នាក់ដឹងថាតើអង្គការដឹកពួកថ្មី ទៅឯណាឡើយ ។

ចុងឆ្នាំ១៩៧៨... ពួកយួនវាយលុកចូលស្រុកខ្មែរ ។ អាខ្មែរក្រហមឮតែយួន នាំគ្នារត់ប្រាស់អាយូស ។ ពួកអាស្អីគេនេះ បានតែជាមួយខ្មែរគ្នាឯងទេ ។ គ្រួសារខ្ញុំព្រមទាំងអាឆៃនាំគ្នារត់ចេញពីភូមិសំខៅទៅក្រុងកំពង់ចាម ។ ខ្ញុំនាំកូនប្រពន្ធទៅនៅភ្នំពេញ ចំណែកអាឆៃត្រឡប់ទៅភ្នះប្រពន្ធវានៅបឹងកុក រង់ចាំមើលប្រពន្ធកូនវា ។

៦ខែក្រោយមក ខ្ញុំទៅដល់ជំរំខៅអ៊ីដាងឯស្រុកសៀម ។ ជនភៀសខ្លួនខ្មែរជាច្រើន ម៉ឺននាក់ នាំគ្នារស់នៅយ៉ាងតាន់តាប់ក្នុងជំរំ ដែលសង់នៅលើផែនដីដ៏ធំធេង ។ នៅក្នុងជំរំគេឃើញមានវិហារកាតូលិកមួយយ៉ាងធំ ។ ជនភៀសខ្លួន ជាច្រើនរយនាក់ បាននាំគ្នាចូលសាសនាកាតូលិក ដោយសង្ឃឹមយ៉ាងមាំថា ព្រះយេស៊ូគ្រីស្ត មុខជានឹងជួយគេឱ្យឆាប់បានចេញពីជំរុំ ទៅកាន់ប្រទេសទី៣ មានអាមេរិក បារាំង ជាដើម ។ ព្រឹកថ្ងៃមួយនោះ នៅពេលខ្ញុំដើរលេងក្នុងជំរុំ ស្រាប់តែវូមវាក់នឹងអាឆៃ ។ វាកាន់គម្ពីរ "ប៊ីប" (Bible) មួយយ៉ាងធំនៅដៃស្តាំ ។ អាឆៃស្ទុះមកអោបខ្ញុំ ទាំងទឹកភ្នែក ។

-អាសម្លាញ់ (អាឆៃនិយាយ) អឺយ ប្រពន្ធកូនអញពិតជាស្លាប់អស់ហើយ មើលទៅ ព្រោះអញខំដើររកតាំងពីកំពង់ចាម រហូតដល់ភ្នំពេញ មិនឃើញសោះ ។

ខ្ញុំអាណិតអាឆៃ ស្ទើរខ្លោចចិត្ត ។

-ឯងឥឡូវចូលយីស៊ូហើយឬអាឆៃ ? (ខ្ញុំសួរទៅវា) ។

អញដាច់ចិត្តចូលកាតូលិកហើយ ព្រោះព្រះ(ពុទ្ធ) ឥតជួយអញទេ ។ អញនៅវត្តប្រឹងបំរើព្រះ(ពុទ្ធ) សឹងស្លាប់ ព្រះ(ពុទ្ធ) ឥតជួយអញសោះ ។ អញតូចចិត្តនឹងព្រះ(ពុទ្ធ) ខ្លាំងណាស់ ។

មួយអាទិត្យក្រោយមក អាឆៃរត់មករកខ្ញុំ ទាំងរពឹករពហាម ៖

-អាសម្លាញ់ អញឃើញប្រពន្ធកូនអញហើយ ។ ឥឡូវនេះគ្រួសារអញនៅសង្កាត់លេខ២ ។ តែសំណាងអាក្រក់ណាស់ ម្ដាយក្មេកអញនៅរស់ ហើយគាត់មិនព្រមឱ្យអញរួមរស់ជាមួយប្រពន្ធអញទេ ព្រោះគាត់ថាអញជាកូនអកតញ្ញូកាលនៅជំនាន់អាពត ។

នៅពេលខ្ញុំជួបប្រពន្ធអាឆៃលីងរលោង និយាយមកកាន់ខ្ញុំ៖

-ពូវាអើយ ម៉ែគាត់ប្រកាន់ខឹងនឹងឪវា ឱ្យខ្ញុំលែងគាត់ ។ ខ្ញុំលែងប្ដីមិនកើតទេ តែម្ដាយខ្ញុំចាស់ ហើយឈឺទៀតផង ។ ដូចនេះ ខ្ញុំសុខចិត្ត ធ្វើតាមគាត់មួយគ្រាសិន ដល់គាត់អស់ជីវិត ខ្ញុំមុខជាទៅរកឪវាវិញហើយ ។ ពូវាអើយជួយទៅពន្យល់ប្ដីខ្ញុំផង ។

ខ្ញុំយករឿងនេះមកប្រាប់អាឆៃ ។

-តើថ្ងៃណាទៅអាំ បានគាត់ងាប់?(អាឆៃនិយាយមកកាន់ខ្ញុំ) ។

កន្លះឆ្នាំក្រោយមក ម្ដាយក្មេកអាឆៃក៏បានចែកស្ថានទៅមែន ។ អាឆៃក៏បានទៅជួបជុំគ្រួសារវាជាថ្មី ម្ដងទៀត ។ ជួបគ្នាម្ដងនេះ ពិតជាជួបរហូត ជួបដល់ខាំចេករបូត ខាំពោតរបេះ ។

ថ្ងៃមួយ នៅពេលគ្រួសារយើងទាំងពីរជួបជុំគ្នា ខ្ញុំនិយាយទៅកាន់ប្រពន្ធអាឆៃ៖

-មីងវាដឹងទេ អាឆៃវាមានបាប ព្រោះកាលនៅវត្តថ្មគោល និងបឹងកុក វាបាននាំខ្ញុំលួចស៊ីបាយមុនលោក ។ ព្រះ(ពុទ្ធ) លោកខ្វាល់ទើបដាក់ទណ្ឌកម្មវា ។ រឿងម្ដាយក្មេកអាឆៃធ្វើបាបកូនប្រសារ អ្នកនៅក្នុងជុំរុំគេដឹងឮសឹងគ្រប់គ្នា ។៚